ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

L20230130008T2847

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំ២០២៣

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣



©ប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមបណ្ឌិតសភាចារ្យ **វង្ស វិសុទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួល

បន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមរបស់ឯកឧត្តមអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ តំណាងអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ព្រមទាំងវត្តមានចូលរួមរបស់ឯកឧត្តមទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម-លោកជំទាវអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ សាខាពន្ធដារខេត្ត-ខណ្ឌ និងការចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) របស់ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ចំពោះលទ្ធផលប្រមូលពន្ធក្នុងខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **គង់ វិបុល** បានបង្ហាញនូវចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ដាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមាន **៩៧៥,៤៦ ប៊ីលានរៀល** (ប្រមាណជា **២៤០,៨៥ លានដុល្លារ**) ស្មើនឹង **៨,៥៤%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ ប្រៀបធៀបនឹងចំណូលពន្ធ-អាករប្រចាំខែធ្នូ ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន **៧៧,៦៤ ប៊ីលានរៀល** (ប្រមាណជា **១៩,១៧ លានដុល្លារ**) ស្មើនឹង **៨,៦៥%**។ សរុបរយៈពេល ១២ខែ ឆ្នាំ២០២២ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានដាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **១៣ ៩៩៣,២០ ប៊ីលានរៀល** (ប្រមាណជា **៣ ៤៥៥,១១ លានដុល្លារ**) ស្មើនឹង **១២២,៥៤%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២២ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន **២ ៧០២,៧៣ ប៊ីលានរៀល** (ប្រមាណជា **៦៦៧,៣៤ លានដុល្លារ**) ស្មើនឹង **២៣,៩៦%**។ លើសពីនេះ សម្រាប់រយៈពេល ១២ខែ ក្នុងឆ្នាំ២០២២ ចំណូលពីប្រភេទពន្ធសំខាន់ៗបានរក្សាកំណើនធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ក្នុងនោះពន្ធលើប្រាក់ចំណូល **២៣,៧៣%** អាករលើតម្លៃបន្ថែម **៣៤,១០%** ពន្ធលើប្រាក់បៀវត្ស **២២,៤៥%** អាករពិសេស **២៥,៧០%** និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់អចលនទ្រព្យ **១២,៧០%**។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថាលទ្ធផលជាទីមោទនៈនេះ គឺមិនអាចកាត់ផ្តាច់ចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការគ្រប់គ្រងស្ថានការណ៍នៃជំងឺកូវីដ-១៩ បានពេញលេញនិងមានប្រសិទ្ធភាពខ្ពស់តាមរយៈការចាត់វិធានការជាយុទ្ធសាស្ត្រក្នុងការចាក់វ៉ាក់សាំងជូនប្រជាជនកម្ពុជាប្រកបដោយស្មារតីបុរេសកម្មនិងទាន់ពេលវេលា ដែលអាចកសាងភាពស៊ាំក្នុងសហគមន៍ទៅនឹងជំងឺកាចសាហាវនេះ ហើយឈានទៅបើកប្រទេសជាតិឱ្យដំណើរការសេដ្ឋកិច្ច-សង្គមឡើងវិញកាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅនេះ ហើយបាននិងកំពុងអនុវត្តការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។ បន្ថែមពីនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានយកចិត្តទុកដាក់លើការគ្រប់គ្រងប្រមូលចំណូលពន្ធ ដែលតែងតែដឹកនាំចង្អុលបង្ហាញប្រកបដោយភាពឈ្លាសវៃ និងការដាក់ផែនការយ៉ាងមុតស្រួចលើការអនុវត្តកំណែទម្រង់សំខាន់ៗ និងវិធានការជាយុទ្ធសាស្ត្រនាពេលកន្លងមក ដែលបានជំរុញនិងលើកកម្ពស់អនុលោមភាពសារពើពន្ធ និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមមជ្ឈដ្ឋានវិនិយោគ។




## លទ្ធផលការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបានក្នុងឆ្នាំ២០២២៖

- **បានអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** ដែលជាគោលការណ៍ស្នូលនៃកំណែទម្រង់និងទំនើបកម្មនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីឈានទៅបង្កើតប្រព័ន្ធពន្ធដាររឹងមាំ និងបង្កភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការបង់ពន្ធ
- **បានរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing)** ដែលមានលក្ខណៈពេញលេញ ជួយសម្រួលនិងផ្តល់លទ្ធភាពឱ្យអ្នកជាប់ពន្ធដាក់លិខិតប្រកាសពន្ធតាមអនឡាញបានយ៉ាងលឿន ចំណេញពេលវេលាមានតម្លាភាពខ្ពស់ ព្រមទាំងជំរុញពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធ ជាពិសេសក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩
- **បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី** ដែលឆ្លើយតបនឹងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច ព្រមទាំងធានាបាននូវភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសង្គតិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ
- **បានរៀបចំនិងបញ្ចប់ការចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA)** ជាមួយប្រទេសតួកគី និងតំបន់រដ្ឋបាលពិសេសម៉ាកាវ និងបានបន្តជំរុញការងារចរចាចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសនានា
- **បានបន្តកិច្ចសម្រួលជូនវិស័យឯកជន** តាមរយៈការរៀបចំវគ្គផ្សព្វផ្សាយបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារ និងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជាប្រចាំ
- **បានសហការសម្របសម្រួលជាមួយធនាគារជាតិនៃកម្ពុជា** ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ ក្នុងគោលដៅចៀសវាងការខាតបង់ចំណូលពន្ធដោយសារគម្លាតនៃអត្រាប្តូរប្រាក់
- **បានដឹកនាំគណៈប្រតិភូរបស់អគ្គនាយកដ្ឋានពន្ធដារចូលរួមកិច្ចប្រជុំលើកទី៥១នៃក្រុមសិក្សាពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិកនិងការស្រាវជ្រាវ (SGATAR)** ដើម្បីចែករំលែកពីវឌ្ឍនភាព និងនិន្នាការថ្មីនៃវិស័យពន្ធដារ
- **បានសិក្សាស្រាវជ្រាវ និងរៀបចំរួចរាល់នូវសេចក្តីព្រាងប្រកាសស្តីពីវិធាននិងនីតិវិធីសម្រាប់អនុវត្តកាតព្វកិច្ច**

**សារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្មល្បែងពាណិជ្ជកម្ម (Casino)** ដើម្បីជំរុញនិងពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសក្នុងវិស័យនេះ

- **បានបន្តជំរុញនិងបញ្ចប់ការដំឡើងឧបករណ៍វាស់ចំណុះ (Flow Meter) ស្រាបៀរ និងភេសជ្ជៈគ្មានជាតិស្រា** នៅតាមគ្រប់រោងចក្រផលិតស្រាបៀរនិងភេសជ្ជៈគ្មានជាតិស្រាទាំងអស់ ដើម្បីធានាឱ្យបាននូវអនុលោមភាពសារពើពន្ធ និងការប្រកួតប្រជែងដោយស្មើភាពគ្នាសម្រាប់វិស័យនេះ
- **បាននិងកំពុងបន្តកិច្ចសហការលើការងារប្រឆាំងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ** រួមមាន (១).ការបន្តស្រាវជ្រាវធ្វើការស៊ើបអង្កេត និងសហការជាមួយស្ថាប័នពាក់ព័ន្ធ (២). បន្តសហការជាមួយក្រុមការងារស្នូលរបស់ អ.អ.ផ ក្នុងការរៀបចំរបាយការណ៍ និងឯកសារ ដើម្បីត្រៀមលក្ខណៈទទួលការត្រួតពិនិត្យវាយតម្លៃដោយផ្ទាល់ (On-Site Visit) របស់ក្រុមការងារ ICRG-JG (៣). ជំរុញការបណ្តុះបណ្តាល និងបន្តលើកកម្ពស់ការយល់ដឹងអំពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដល់មន្ត្រីរាជការពន្ធដារ និង(៤).ការបន្តខិតខំពង្រឹងកិច្ចសហការជាមួយស្ថាប័នតុលាការ ដើម្បីបង្កើនការបង្កកទ្រព្យ
- **បានអភិវឌ្ឍនិងដាក់ឱ្យប្រើប្រាស់កម្មវិធីវិក្កយបត្រនាំសំណាងពន្ធដារ (GDT Lucky Draw)** ដែលជាគំនិតផ្តួចផ្តើមថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយអនុញ្ញាតឱ្យសាធារណជនទាំងអស់ចូលរួមលើកកម្ពស់វប្បធម៌បង់ពន្ធ
- **បានប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ២០២២** បានចំនួន **៨៨២ ៦០៦ គ្រឿង** ទទួលបានប្រាក់ពន្ធសរុប **៤២២ ១៦៨,៥ លានរៀល** ស្មើនឹង **១៣០.១%** នៃផែនការឆ្នាំ២០២២
- **បានរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធកំណត់ចំណាត់ថ្នាក់នៃកម្រិតប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងទទួលខុសត្រូវរបស់ប្រធានអង្គភាព (Merit and Demerit System - MDS)** ដែលជាយន្តការកំណត់ពិន្ទុរបស់ប្រធានអង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានពន្ធដារទាំងអស់ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការដឹកនាំ
- **បានអនុវត្តផែនការចុះអង្កេតសហគ្រាសតាមដងផ្លូវ (Street Survey) និងផែនការចុះអង្កេតអចលនទ្រព្យ (Property Survey)** ដើម្បីប្រមូល និងធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋបាលសារពើពន្ធ ក្នុងគោលដៅពង្រឹងគុណភាពនៃការផ្តល់សេវា ជូនដល់អ្នកជាប់ពន្ធ
- **បានរៀបចំលិខិតបទដ្ឋានអនុវត្ត និងយន្តការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែមពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)** ដែលជាប្រភពចំណូលថ្មីមួយទៀតជូនរាជរដ្ឋាភិបាល ហើយចំណូលពន្ធប្រមូលបានមានទឹកប្រាក់សរុបចំនួនប្រមាណ **៣៧,៦២ លានដុល្លារ**
- **បានចាប់ផ្តើមអនុវត្តយន្តការបោះពុម្ពវិក្កយបត្របង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់** ដោយធ្វើការចែកជូនដល់គេហដ្ឋានរបស់អ្នកជាប់ពន្ធផ្ទាល់ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការទូទាត់
- **បានរៀបចំតាក់តែង និងបោះពុម្ពឯកសារសំខាន់ៗ** ដូចជា សៀវភៅកំណែទម្រង់ពន្ធដារកម្ពុជា ២០១៣-២០២០ សទ្ទានុក្រមពន្ធដារ សៀវភៅណែនាំស្តីពីគំរូទម្រង់ និងបែបបទការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ និងឯកសារនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) របស់អង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋាន

ពន្ធដារ ដើម្បីបម្រើគុណប្រយោជន៍ដល់វិស័យពន្ធដារកម្ពុជា

- **បានបន្តផ្តល់សេវាពិគ្រោះយោបល់និងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារតាមគ្រប់មធ្យោបាយ** ជាពិសេស ការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) ព្រមទាំងមានការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ
- **បានបន្តអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីសម្រាប់ផ្តល់សេវាអ្នកជាប់ពន្ធ** ដោយបានអភិវឌ្ឍប្រព័ន្ធនិងកម្មវិធីថ្មីជាច្រើនសរុបចំនួន ០៨ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ-កម្មវិធី ចំនួន ៤៣។

ជារួមសម្រាប់លទ្ធផលការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបានក្នុងឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានចងក្រងជាវីដេអូ និងផ្សព្វផ្សាយជាសាធារណៈនៅក្នុងបណ្តាញទំនាក់ទំនងផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ដូចជាគេហទំព័រ(GDT Website) ទំព័រហ្វេសប៊ុកផេក(GDT Facebook Page) តេឡេក្រាមព័ត៌មានពន្ធដារកម្ពុជា និងទំព័រយូធូប (GDT YouTube) របស់អគ្គនាយកដ្ឋានពន្ធដារ។




| មធ្យោបាយ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ | សរុប |
|---|---|---|---|---|---|---|
| ទូរស័ព្ទ (1277) | 64,627 | 81,822 | 53,262 | 26,526 | 6,237 | 232,474 |
| GDT Live Chat | 32,680 | 39,383 | 50,549 | 34,263 | 16,656 | 173,630 |
| បណ្តាញសង្គម Facebook | 4,535 | 3,133 | 2,319 | 508 | 26 | 10,521 |
| កម្មវិធី "ពន្ធដារកម្ពុជា" | 52 | 42 | 41 | 15 | - | 150 |
| កម្មវិធី "រៀនអំពីពន្ធតាមរយៈសំណួរ" | 44 | 42 | - | - | - | 86 |
| GDT News Channel | 4,033 | 2,263 | - | - | - | 6,296 |
| សរុបរួម | 105,971 | 126,665 | 106,271 | 61,332 | 22,921 | 423,160 |
| % ធៀបឆ្នាំកន្លងមក (កើន/ថយ) | -16.34% | 19.19% | 73.27% | 167.58% | - | |

ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៣របស់អគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ ទិមុល** បានប្តេជ្ញាយ៉ាងមុតមាំ និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការងារគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យបានគ្រប់តាមផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ចំនួន **១៤ ៦៤៥,៣៨ ប៊ីលានរៀល** (ប្រមាណ **៣ ៥៣១,៦៥ លានដុល្លារ**) ដោយបន្តពង្រឹងការអនុវត្តនូវវិធានការនិងគោលនយោបាយសារពើពន្ធ ដែលរួមមានវិធានការសំខាន់ៗដូចខាងក្រោម៖

- **បន្តជំរុញបញ្ចប់ការពិនិត្យរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី** ដែលការរៀបចំនេះនឹងអាចធានាបាននូវភាពប្រទាក់ក្រឡានិងបច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីពន្ធដារ
- **បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ** ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាត

ប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ) និង អនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ) ជាពិសេសការត្រៀមលក្ខណៈទទួលការត្រួតពិនិត្យ វាយតម្លៃដោយផ្ទាល់ (On-Site Visit) របស់ក្រុមការងារ ICRG-JG នៅដើមខែមករា ឆ្នាំ២០២៣ ក្នុងគោលដៅឈានទៅដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ

- **បន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់អគ្គនាយកដ្ឋានពន្ធដារ** ដោយប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម ធ្វើយ៉ាងណាឱ្យងាយស្រួល ក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់
- **សិក្សាស្រាវជ្រាវនិងគ្រោងធ្វើទស្សនកិច្ចសិក្សានៅរដ្ឋបាលសារពើពន្ធនៃបណ្តាប្រទេសអភិវឌ្ឍន៍** ដើម្បីស្វែងយល់និងដកបទពិសោធន៍ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំនិងធ្វើបច្ចុប្បន្នភាពយន្តការគ្រប់គ្រងប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេសលើប្រធានបទសំខាន់ៗ ដូចជាយន្តការគ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ពន្ធរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ការប្រមូលចំណូលពន្ធរបស់វិស័យបរធនបាលកិច្ច (Trust) និងវិស័យល្បែងពាណិជ្ជកម្ម ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យាប្លុកឆែន (Blockchain) ក្នុងការប្រមូលចំណូលពន្ធ ជាដើម
- **រៀបចំប្រព័ន្ធដំណើរការការងាររដ្ឋបាលតាមទម្រង់នីតិជិល (E-Administration) និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** ដើម្បីអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធអាចអនុវត្តការងារតាមឋានានុក្រមដោយប្រើប្រាស់ទម្រង់នីតិជិល ដោយធានាបានល្បឿននិងប្រសិទ្ធភាពក្នុងការអនុវត្តការងារ
- **បន្តអនុវត្តនូវវិធានការទារនិងតឹងទារបំណុលពន្ធ**តាមនីតិវិធីជាធរមាន ចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធហើយមិនបានចូលខ្លួនមកទូទាត់ឬដោះស្រាយឱ្យបានត្រឹមត្រូវ
- **បន្តជំរុញដើម្បីបញ្ចប់ការអនុវត្តវិធានការចុះអង្កេតសហគ្រាសតាមដងផ្លូវ (Street Survey) និងវិធានការចុះអង្កេតអចលនទ្រព្យ (Property Survey)**
- **បន្តសហការជាមួយគេហទំព័រ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX)** ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ
- **បន្តពង្រឹងនិងពង្រីកវិសាលភាពអនុវត្តយន្តការបោះពុម្ពវិក្កយបត្រពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងចែកជូនដល់គេហដ្ឋានរបស់អ្នកជាប់ពន្ធ** ឱ្យបានដល់អ្នកជាប់ពន្ធទាំងអស់
- **បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម** តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ បន្តវិនិយោគនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ

- **បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយ**ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ
- បន្តអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងសារាចរណែនាំស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ និងបន្តអនុវត្តដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងថ្លែងកោតសរសើរពីសម្តេចតេជោនាយករដ្ឋមន្ត្រីជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមឯកឧត្តមផ្ទាល់សូមវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការពន្ធដារទាំងអស់ ក្នុងការចូលរួមចំណែកបំពេញភារកិច្ចអស់ពីកម្លាំងកាយចិត្ត និងសម្រេចបានលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធយ៉ាងល្អប្រសើរ ដោយសម្រេចបានលើសផែនការ ទោះបីជាស្ថិតក្នុងសភាពការណ៍លំបាក ប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ច និងនយោបាយសកលយ៉ាងណាក៏ដោយ។

## ប្រសាសន៍សំខាន់ៗរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ

- បានផ្តល់នូវទស្សនទានថ្មីៗនៃសង្គមសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាពសភាពការណ៍ថ្មីនៃសេដ្ឋកិច្ចសកល ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងវិបត្តិនានា ដែលអាចជះឥទ្ធិពលជាអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា។ ក្នុងនោះ វិស័យមួយចំនួនអាចនឹងទ្រឹងនិងបន្តថមថយ ប៉ុន្តែវិស័យខ្លះទៀតអាចកើនឡើងជាដើមមានកំណើន
- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានគាំទ្រលើវិធានការពន្ធដារដែលបានដាក់ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីជាទិសដៅក្នុងការអនុវត្តបន្តសម្រាប់ឆ្នាំ២០២៣
- បន្តពិនិត្យ និងសម្អាតសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធ ដើម្បីត្រៀមដាក់ជូនគណៈរដ្ឋមន្ត្រី និងឆ្លងការពិនិត្យនិងអនុម័តពីរដ្ឋសភាជាតិក្នុងពេលឆាប់ៗខាងមុខនេះ
- បន្តរៀបចំគោលនយោបាយកៀរគរចំណូលសម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧ ដោយមានអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាអគ្គនាយកដ្ឋានស្នូលទទួលបន្ទុកលើកិច្ចការគ្រប់គ្រងប្រមូលចំណូល
- រៀបចំឱ្យបានទាន់ពេលវេលានូវគោលនយោបាយសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងដាក់ឱ្យអនុវត្តឱ្យបានមុនដំណាច់ឆ្នាំ ២០២៣ ដើម្បីអភិវឌ្ឍនិងលើកកម្ពស់សេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យបានកាន់តែរីកធំធាត់ក្នុងក្របខ័ណ្ឌប្រព័ន្ធគ្រប់គ្រងមួយដែលមានប្រព័ន្ធសេដ្ឋកិច្ចផ្លូវការ
- បន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រក្នុងនោះរួមមាន ការសាងសង់សាខាពន្ធដារថ្មី និងការស្វែងរកទីតាំងទីប្រជុំជន ទីរួមស្រុកសម្រាប់រៀបចំការិយាល័យពន្ធដារស្រុក-ក្រុង ដើម្បីពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ បង្កើតសេវាឱ្យកាន់តែកៀកអ្នកជាប់ពន្ធ ក៏ដូចជាគិតគូរដល់ប្រសិទ្ធភាព ផាសុកភាពនៃការបំពេញការងាររបស់មន្ត្រីពន្ធដារ
- លើកវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលដែលទើបតែដាក់ចេញ សម្រាប់បន្តគ្រប់គ្រងផលប៉ះពាល់ និងគាំទ្រការ

ងើបឡើងវិញនៃវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបន្ថកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងបន្តជួយទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ

- ពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធស្របតាមគោលដៅដែលបានដាក់ចេញក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ដើម្បីបំពេញតម្រូវការចំណាយនិងការវិនិយោគរបស់រាជរដ្ឋាភិបាលក្នុងគោលដៅអនុវត្តកម្មវិធីជាច្រើនដើម្បីឆ្លើយតបនឹងអាទិភាពគោលនយោបាយ"មនុស្សនិងកំណើន"រួមមានការដំឡើងប្រាក់បៀវត្សកម្មវិធីជំនួយសង្គម ការរៀបចំការបោះឆ្នោត និងការរៀបចំព្រឹត្តិការណ៍នៃការប្រកួតស៊ីហ្គេមជាដើម
- បន្តអនុវត្ត និងធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវការចុះបញ្ជីតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDx) ដើម្បីសម្រួលកិច្ចពាណិជ្ជកម្ម និងធុរកិច្ចនៅកម្ពុជា
- បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធពីប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) តាមរយៈការពង្រឹងនិងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធបន្ថែមទៀត និងត្រូវបន្តការគិតគូរជាជំហានៗពាក់ព័ន្ធនឹង Internet Gateway និង Payment Gateway
- ប្រព័ន្ធទូទាត់បាគងរបស់ធនាគារជាតិនៃកម្ពុជានឹងក្លាយជាគុណប្រយោជន៍មួយដ៏សំខាន់សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ក្នុងយន្តការនៃការគ្រប់គ្រងលើការទូទាត់
- បន្តកែលម្អបន្ថែមទៀតលើការធ្វើទំនើបកម្ម និងការកសាងសមត្ថភាពមន្ត្រី ដែលជាកត្តាដ៏សំខាន់ក្នុងការចូលរួមលើកកម្ពស់អនុលោមភាពសារពើពន្ធ និងការផ្តល់សេវាជូនអ្នកជាប់ពន្ធ
- បន្តលើកកម្ពស់និងបញ្ញាវប្បធម៌ពន្ធដារ តាមរយៈការបង្កើនការយល់ដឹង ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិពន្ធដារជូនដល់មន្ត្រីអនុវត្តផ្ទាល់អ្នកជាប់ពន្ធ និងសាធារណជន ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ
- បន្តបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រី ក្នុងគោលដៅពង្រឹងសមត្ថភាពស្ថាប័ន សេវាជូនអ្នកជាប់ពន្ធកាន់តែល្អប្រសើរ តាមរយៈការកាត់បន្ថយការយើសចិត្តពីអ្នកជាប់ពន្ធ។

ជាកិច្ចបញ្ចប់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ជាថ្មីម្តងទៀតបានកោតសរសើរវាយតម្លៃខ្ពស់ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់នៅតាមអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូល ដែលទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ហើយនេះគឺជាជោគជ័យ និងជាសមិទ្ធផលរួមរបស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល និងសូមជូនពរថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារជួបតែវិបុលសុខ និងសម្បូរកបរដោយពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។